# ដំណាំឪឡឹក

Watermelon

## I. ស្ថានភាពទូទៅ

មានដំណាំយកផ្លែជាច្រើនប្រភេទដែលត្រូវស្ថិតនៅក្នុងក្រុមបន្លែផង និង ជាដំណាំហូបផ្លែផងដែរ ដូចជា ដំណាំឪឡឹកជាដើម វាត្រូវបានគេបរិភោគផ្លែខ្ចីៗ ក្នុងតំបន់ប្រទេសត្រូពិចមួយចំនួន ដែលមិនសំបូរបន្លែ ប៉ុន្តែដោយ ឡែកប្រទេសភាគច្រើនគេតែងតែបរិភោគផ្លែទុំជាបង្អែម ហើយមានប្រជាប្រិយ៍ភាពយ៉ាងខ្លាំង ស្ទើរពេញពិភពលោក ។






ការនិយមចូលចិត្តបរិភោគ ដោយយោងទៅលើរសជាតិ និង សារធាតុផ្សេងៗសម្រាប់ទ្រទ្រង់រាងកាយដូចក្នុងតារាងអាហាររូបត្ថម្ភ។ តារាងអាហារូបត្ថម្ភក្នុងទំងន់ ១00 ក្រាម បរិភោគបាន.

| ១00ផ្លែទុំ | ទឹក | ថាមពល | ប្រូតេអ៊ីន | ប្រេង | វីតាមីន B | វីតាមីន C | Ca | Fe |
|---|---|---|---|---|---|---|---|---|
| ខ្នាត | ក្រាម | គីឡូ | ក្រាម | ក្រាម | មីលីក្រាម | មីលីក្រាម | មីលីក្រាម | មីលីក្រាម |
| បរិភោគបាន | ៩៥ | ៣.៣ | 0.២ | 0.២ | 0.0៤ | ១ | ១១ | ៧.៩ |

## II. បច្ចេកទេសដាំដុះ

### ១.ការជ្រើសរើសពូជ

នៅក្នុងការដាំដុះពូជជាកត្តាសំខាន់យ៉ាងចំបងជាងគេ ហើយមានជាច្រើនប្រភេទមានពូជស្រាល កណ្តាល និងធ្ងន់ ពូជទាំងនេះមិនអាចសមស្របក្នុងការដាំដុះគ្រប់តំបន់នោះឡើយ មានពូជខ្លះសមស្របនឹងអាកាសធាតុ ត្រជាក់ ពូជខ្លះសមស្រប និងអាកាសធាតុក្តៅ ហើយសុទ្ធសឹងជាពូជកូនកាត់ Hybrid F1 មិនអាចយកគ្រាប់មក ទុកពូជបន្តបានឡើយ ព្រោះវាត្រូវបានផលិតដោយក្រុមហ៊ុនជាច្រើនលើពិភពលោក។ ប៉ុន្តែក្នុងនោះពូជដែលផលិត ដោយក្រុមហ៊ុន នៅតំបន់អាស៊ី ដូចជាជប៉ុនតៃវ៉ាន់ ចិន ថៃ វៀតណាម ភាគច្រើនអាចដុះលូតលាស់ល្អក្នុងប្រទេសកម្ពុជាយើង ដោយឡែកពូជប្រពៃណី



ដែលធ្លាប់បានដាំដុះនៅក្នុងតំបន់ជុំវិញទន្លេសាប មុនសម័យសង្គ្រាមត្រូវផុតពូជទាំងស្រុងជាពិសេសនៅតំបន់ព្រៃប្រទល់ ខេត្តកំពង់ធំ និងខេត្តសៀមរាប (កំពង់ឃ្លាំង ដំដែក កំពង់ចិន វាលក្រោម) ។ វិធីសាស្ត្រក្នុងការជ្រើសរើសពូជមាន :ត្រូវយល់ដឹងពីប្រភពថ្ងៃ ខែ ឆ្នាំផលិត ភាពសុទ្ធ អាយុកាលលូតលាស់ជាពិសេសគឺពូជដែលបានណែនាំអោយប្រើប្រាស់ ។

## ២.ការជ្រើសរើស និងរៀបចំដី

- ការជ្រើសរើសដី : ដើម្បីអោយការដាំដុះទទួលបានជោគជ័យល្អ គេត្រូវជ្រើសរើសដីដោយផ្អែក តាមលក្ខខណ្ឌ ដូចតទៅ: ប្រភេទដីល្បប់ដីល្បាយខ្សាច់ ដីក្រហមជើងភ្នំ ដីខ្មៅខ្ពង់រាប ដែលមានជីជាតិល្អ ស្រទាប់ ដាំដុះជ្រៅជ្រាបទឹកបានរហ័ស ដែលមាន PH ពី ៥-៦.៨ ជាមធ្យម ជាពិសេសគឺមិនត្រូវយកដីដែលដាំដំណាំអំបូរ ត្រសក់ ននោង ល្ពៅ ម្រះ ឃ្លោក ពីរដូវមុន មកដាំឱ្យឡើកឡើយ ហើយម្យ៉ាងទៀតវាមិនឆ្លើយតបទៅលើប្រភេទ ដីឥដ្ឋខ្លាំងឡើយ ដែលហៅថា Glay Soil ។

- ការរៀបចំដី: ដំបូងត្រូវរាស់យកកាកសំណល់ផ្សេងៗ និង ស្មៅចង្រៃចេញពីចំការអោយស្អាត បន្ទាប់មកភ្ជួរដី ហាលឱ្យបានយូរថ្ងៃធ្វើអោយដីស្ងួតសំលាប់ពពួកសត្វល្អិត និងកត្តាចង្រៃផ្សេងៗ ក្រោយមក រាស់បំបែកដីអោយល្អិត និងកៀរឱ្យស្មើ ។ ការភ្ជួរ និង រាស់ត្រូវធ្វើឡើងឱ្យបានចំនួន ២-៣ ដងធ្វើអោយដីធូរ





មានបន្ទុកខ្យល់គ្រប់គ្រាន់ ។ ក្រោយពីភ្ជួរ និង រាស់រួចហើយត្រូវលើករងដោយនង្គ័លគោ ត្រាក់ទ័រ គោយន្ត ឬ ដោយចបឱ្យមាន ទទឹងរង ១.៥ ម កំពស់រង ២៥-៣០ សង់ទីម៉ែត្រ បន្ទាប់មកយកជីធម្មជាតិ ឬជីកំប៉ុស្តិ៍មកដាក់ចំកណ្តាលរង ដោយ ប្រើ១៨-២០តោន និងជី ១៥ .១៥ .១៥ ចំនួន ២០០គក្រ លើផ្ទៃដី ១ ហត ក្រោយមកពូនរងលប់ដីឱ្យ ជិតកៀរអោយស្មើ ហើយគ្របចំបើងឬគ្របកៅស៊ូ (កៅស៊ូសម្រាប់គ្របដីដាំដំណាំ) ឱ្យជិតទើបធ្វើការដាំដុះបាន ។

## ៣.ការដាំដុះ

គេអាចដាំដុះស្ទើរពេញ១ឆ្នាំ ប៉ុន្តែសំខាន់បំផុតគឺវាអាស្រ័យទៅតាមតំបន់ តំបន់វាលរាប និងមាត់ទន្លេបា សាក់ មេគង្គ និងទន្លេសាបគេអាចដាំពីខែតុលា វិច្ឆិកា ធ្នូ និង មករា និងប្រមូលផលនៅខែធ្នូ ខែ មករា និងកុម្ភៈ ។ ប៉ុន្តែចំពោះតំបន់ខ្ពង់រាបនិងតំបន់ភ្នំគេអាចដាំពីខែឧសភា មិថុនា កក្កដា សីហា កញ្ញា និង ខែ តុលា ។ ការជ្រើសរដូវកាល គឺសំដៅទៅលើលក្ខខណ្ឌអាកាសធាតុ វាអាចដុះលូតលាស់ចន្លោះពី ១៥ °C ទៅ ៣៥ °C ។ សីតុណ្ហភាពសំរាប់ដំណុះល្អ ២០-២២ °C ដំណាក់កាលចេញផ្កា ២៤ °C ទៅ ២៧ °C វគ្គទុំ ២៧-៣០ °C ពេលយប់យូរសីតុណ្ហភាព ២០-២៤ °C និងពេលថ្ងៃ ២៥ ៣០ °C អាចធ្វើអោយវាទុំក្រហមល្អ ជាតិស្ករច្រើន វាត្រូវការទឹកភ្លៀងក្នុងដំណាក់

កាលលូតលាស់ រយៈពេល៣ខែ ចំនួន ១២០-១៨០មម ជាមធ្យមប្រចាំឆ្នាំ ១២០០មម និងសំណើមបរិយាកាស ៥០%ជាមធ្យម ។ គេអាចដាំឪឡឹក តាមច្រើនវិធី អាស្រ័យទៅតាមតំបន់ ដាំដុះគឺដាំដោយគ្រាប់ផ្ទាល់និងដាំដោយ កូនបណ្តុះ ។



**ក. ការដាំដោយគ្រាប់ផ្ទាល់ :** មុនពេលដាំ គេត្រូវយកគ្រាប់ពូជទៅហាលថ្ងៃ រយៈពេល២ម៉ោង បន្ទាប់មក យកគ្រាប់ពូជទៅត្រាំជាមួយសូលុយស្យុង Captan៥០% wp រយៈពេល ២៥-៣០ នាទី ឬគេអាចយក Captan ២,៥-៣ ក្រាម លាយជាមួយ គ្រាប់ពូជទំងន់ ១គក្រ ទើបយកទៅដាំ ។ មុនដាំគេកាប់រណ្តៅនៅលើរងចន្លោះ ១ម ជំរៅរណ្តៅ ៧-៨សម បន្ទាប់មកថ្នាំប្រភេទ Furadan 3H ចំនួន១០គក្រ១ ហត ដាក់បាតរណ្តៅ បន្ទាប់មកទើបដាំ ១រណ្តៅ ២-៣ គ្រាប់ ហើយគ្របកំទេចចំបើងស្ងួតពីលើ ទើបស្រោចទឹកតាមក្រោយមួយថ្ងៃពីរលើក ។

**ខ. ការដាំដុះដោយកូនបណ្តុះ** ក្រោយពីយកគ្រាប់ពូជទៅត្រាំ និង សូលុយស្យុង Captan រួចមកគេយកទៅបណ្តុះក្នុងកន្ទោងស្លឹក ត្នោត ស្បោងកៅស៊ូដែលច្រកបំពេញ ដីដែលបានផ្សំជាមួយជីជាតិ ៥ % កំប៉ុស្តិ៍ ៣ភាគ ដីខ្សាច់ ១ ភាគ និងអង្កាម ១ភាគ លាយបញ្ចូលគ្នា ហើយដាក់គ្រាប់ពូជ ២-៣គ្រាប់ ក្នុងមួយកន្ទោង



ហើយយកទៅតំរៀប នៅកណ្តាលវាលគ្របចំបើងស្ងួត បន្ទាប់មកស្រោចទឹកអោយជោគព្រឹក ល្ងាច ។ ៤៨ ម៉ោងក្រោយមកយកចំបើងនោះ ចេញ បន្ទាប់មកទៀត រយៈពេល៤ថ្ងៃ គេស្រោចសូលុយស្យុង Captan . zineb. Maneb. Mancozeb or Benomyl លាយក៏រិត ១០គក្រ និងថ្នាំពុលប្រភេទ Dimethoad ១០ CC លាយទឹក ១៥ លីត្រ ទើបអាចយកទៅដាំបានគេដាំមិនឱ្យលើសពី ៤-ថ្ងៃ ក្រោយបណ្តុះឡើយ គឺឪឡឹកមានស្លឹក Decotyledon ២ ធម្មតា ។ ១ហតគេប្រើគ្រាប់ពូជ ២-៣ គក្រ ។



### ៤.ការស្រោចស្រព

ដំណាំនេះត្រូវការទឹកជាមធ្យមចាប់ពីពេលវាដុះរហូតដល់វាចេញផ្កាឈ្មោល តែក្រោយពីឪឡឹកមានក្តិបវា ត្រូវការទឹកកាន់តែខ្លាំង រហូតដល់ពេលផ្លែចាប់ផ្តើមដាក់ជាតិស្ករ។ គេអាចស្រោចរៀងរាល់ថ្ងៃរឺ២ ថ្ងៃម្តង ទៅតាម ប្រភេទដី និងអាកាសធាតុ។ ប៉ុន្តែវាអាចរស់ដោយសារទឹកភ្លៀង ឬសំណើមដីប្រមាណ ៧០-៨០% ។ ចំពោះការ ដាំលើដីល្បាប់ ល្បាយខ្សាច់តាមមាត់ទន្លេគេដាំមិនប្រើប្រពន្ធ័ស្រោចស្រពឡើយ ភាគច្រើនប្រើប្រាស់សំណើមក្នុងដី ជាធម្មជាតិ និងសំណើមបរិយាកាស រហូតដល់ឪឡឹកជិតបានប្រមូលផលនោះទើបគេបន្ថយការស្រោចទឹក ។

### ៥.ការជ្រុំជ្រោយដី

ប្រយោជន៍នៃការជ្រុំជ្រោយដី គឺធ្វើអោយដីធូរ បន្ថយការដុះស្មៅ សំរួលដល់

បន្ទុកខ្យល់ចេញចូលបានល្អ ធ្វើអោយដីរក្សាសំណើមបានយូរ បង្កអោយសារធាតុរលួយបានលឿន ឫសឪឡឹកលូតលាស់ល្អ ស្រូបយកជីជាតិ បានរហ័សទៅចិញ្ចឹមសរីរាង្គ។ របៀបជ្រុំជ្រោយដី គឺគេជ្រុំឱ្យផុសដីពេញផ្ទៃរង ហើយពូនលប់គល់ឪឡឹកអោយ ជិតរយៈពេល ១៥-១៨ថ្ងៃ ក្រោយដាំ ។ ក្រោយពីជ្រុំហើយត្រូវកាត់ស្លឹក និង ខ្នែងដែលដុះពីថ្នាំងទី ១-២-៣ចេញបន្ទាប់មកកប់ទងឪឡឹកទៅក្នុងដី ដើម្បីអោយឫសថ្មីដុះចេញពីថ្នាំងទាំងនោះ ជំនួយដល់ការដុះលូតលាស់បន្ថែមទៀត ។

### ៦.ការដាក់ជីបំប៉ន

ឪឡឹកក៏ដូចជាដំណាំឯទៀតដែរ វាទាមទារអោយមានការ ផ្តល់ជីអោយបានគ្រប់គ្រាន់ទៅតាមតំរូវការ របស់វាក្នុងវគ្គនិមួយៗ ដូចនេះគេចែកចេញការដាក់បន្ថែមជីចំនួន ៣ លើកដូចតទៅ :

- ការស្រោចបំប៉នលើកទី១: នៅក្នុងវគ្គនេះឪឡឹកត្រូវការសារធាតុអាសូត (N) ច្រើនជាងគេ ក្នុងកំឡុង ១០ថ្ងៃ ក្រោយដាំ ដូចនេះត្រូវយកជីអ៊ុយរ៉េ ចំនួន









១៥ក្រាម លាយទឹក ២០លីត្រ ស្រោចចំគុម្ព ហើយស្រោចទឹក លាងតាមក្រោយ ក្នុង១ហត អាចប្រើជីអស់ចំនួន ៣៥-៤០ គក្រ ។

- ការដាក់បំប៉នលើកទី២: នៅក្នុងវគ្គនេះវាត្រូវការសារធាតុទាំងបីមុខគឺ អាសូត(N) ផូស្វ័រ(P) និងប៉ូ តាស្យូម (K) ដូចនេះគេត្រូវយកជី ១៥ ១៥ ១៥ ចំនួន ២៥-៣០ ក្រាម ក្រោយពីដាំបានរយៈពេល ២០-២៥ថ្ងៃ ដោយដាក់ជុំវិញគល់ហើយកាយដីលប់ឱ្យជិតនិងស្រោចទឹកឱ្យជោគក្នុង១ហតអាចប្រើ ២០០-២៥០គក្រ។

-ការដាក់បំប៉នលើកទី៣: នៅក្នុងវគ្គចុងក្រោយនេះគេតែងតែដាក់ជី២ប្រភេទរួមគ្នា គឺជីអ៊ុយរ៉េ និង ជី ប៉ូតាស្យូម ដើម្បីអោយឪឡឹកទុំក្រហមហើយមានរស់ជាតិផ្អែម។ ចំនួនជីអ៊ុយរ៉េពី ៤៥-៥០គក្រ ជី $K_2O$ = ៥០% ចំនួន ៤៥-៥០ គក្រ លាយបញ្ចូលគ្នា ហើយដាក់លើផ្ទៃដី ១ហត ក្រោយពីឪឡឹកផ្លែធំ (តាមប្រភេទពូជ) មុនប្រមូលផលពី ១៥-២៥ថ្ងៃ។

## III. អំពីជំងឺ និងវិធានការការពារ

ឳឡឹកតែងទទួលរងនូវជំងឺជាច្រើន ប្រភេទដែលបង្កឡើងដោយមេរោគ ៣ ក្រុមធំៗ គឺក្រុមបង្កដោយ វីរុស ផ្សិត និងបាក់តេរី ......... ។

**១. ក្រុមជំងឺបង្កដោយវីរុសៈ** វីរុសដែលតែងតែកើតលើដំណាំឳឡឹកមានពីរប្រភេទដែលសំខាន់គឺៈ

- វីរុសបង្កឱ្យរួញត្រួយ ៈ មានឈ្មោះហៅថា Papaya Ring Spot Virus គេតែងសង្កេតឃើញ ត្រួយខ្ចីៗ របស់ឳឡឹករួញហើយងើបទងឡើងលើ ស្លឹកដែលលូតលាស់ចេញមករួញក្រញាញ់ ជាពិសេសនៅក្នុង វគ្គកំពុងចេញផ្កា និងផ្លែខ្ចីៗ ធ្វើឱ្យថយចុះនូវការបន្តពូជផ្លែមិនរីកធំធាត់បាន ហើយផ្លែទុំគ្មានរសជាតិ ផ្លែបាត់បង់ ទិន្នផលយ៉ាងច្រើន......។

- វីរុសបង្កអោយរួញស្លឹកៈ មានឈ្មោះហៅថា Watermelon Mosaic គេសង្កេតឃើញស្លឹកឳឡឹកប្រែពណ៌ពីបៃតងទៅបៃតងចាស់ ហើយក្រាស់បន្ទាប់មករួញស្លឹកក្តោបចុះមកក្រោម នៅក្នុងវគ្គចេញផ្លែ ធ្វើអោយផ្លែ ប្រែប្រួលទំរង់ទៅជាក្រិន លែងរីកលូតលាស់ សំបករឹង ពន្យាពេលទុំ ហើយគ្មានរសជាតិ បាត់បង់ទិន្នផលយ៉ាងច្រើនកាលណារងការបំផ្លាញ ដោយជំងឺនេះ។ ជំងឺទាំងពីរប្រភេទនេះតែងតែបង្កឡើងដោយចៃពីរប្រភេទគឺ ចៃខ្មៅ និង ចៃបៃតង។ ដើម្បីទប់ទល់ទៅ នឹងជំងឺនេះគេប្រើប្រាស់ពូជធន់ទ្រាំ ត្រួតពិនិត្យវគ្គមានចៃអោយបានត្រឹមត្រូវ និង ទាន់ពេលវេលាហើយដកដើមដែលកើតជំងឺយកទៅដុតចោល និងត្រូវប្តូរដីដាំដុះ ។



**២. ក្រុមជំងឺបង្កដោយមេរោគផ្សិត ៈ** មានជំងឺផ្សិតជាច្រើនប្រភេទដែលបំផ្លាញដំណាំឳឡឹក ចាប់ពីវគ្គដុះពន្លក រហូតដល់ពេលប្រមូលផលក្នុងនោះមាន ៈ

- ផ្សិតបង្កដោយរលួយកូនៈ មានឈ្មោះហៅថា Damping 0ff បង្កដោយមេរោគបីប្រភេទគឺ Rhizoctonia solani, Pythium spp និង Cercospora spp. តែងតែធ្វើអោយរលួយគល់កូនឳឡឹកក្នុងកំឡុងអាយុកាលពី ៥-១០ថ្ងៃ។

- ជំងឺបង្កឱ្យពុកឫសៈ មានឈ្មោះហៅថា Fusarium Wilt វាបង្កដោយមេរោគ Fusaium Oxysporum f.sp.neveum ។ គេសង្កេតឃើញកើតជាញឹកញាប់នៅរដូវក្តៅសើម នៅក្នុងវគ្គកំពុងបន្តពូជ ធ្វើអោយ ពុករលួយដើម ហើយស្រពោនលែងលូតលាស់បន្ត ។

- ផ្សិតបង្កដោយមានប្រជ្រុយស្លឹក ៈ មានឈ្មោះហៅថា Alternaria leaf spot វាបង្កឡើងដោយមេរោគឈ្មោះ Alternaria cucumerina ជាពិសេសនៅក្នុងវគ្គជិតប្រមូលផល ធ្វើឱ្យលេចឡើងនូវស្នាមអុចៗ ដូចប្រជ្រុយពណ៌ត្នោតភ្លឺពេញផ្ទៃស្លឹកបន្ទាប់មកស្លឹកនោះនឹងស្ងួត ធ្វើឱ្យ

- ជំងឺខ្មៅស្លឹកនិងដើម ៈ មានឈ្មោះហៅ



ថា Gummy Stem Blight វាបង្កឡើងដោយមេរោគឈ្មោះ Dedymella bryoniae ច្រើនតែកើតនៅរដូវវស្សាធ្វើអោយស្លឹកលេចចេញចំនុចពណ៌ខ្មៅដូចធ្យូងផ្ទាំងៗ ធំៗព្រមទាំងដើមដុះផ្សិតខ្មៅធ្វើអោយឪឡឹកងាប់ពាក់កណ្តាលដើម ។

-វិធានការការពារនិងកំចាត់: មុននឹងដាំយកគ្រាប់ពូជត្រាំទឹកក្តៅកំដៅ ៥០°C រយៈពេល ១៥-២០នាទី លាងសំអាតគ្រាប់ឱ្យស្អាត និងឧបករណ៍ បណ្តុះត្រូវសម្លាប់មេរោគជាមុន ក្រោយពីដុះបានរយៈពេល៥-៧ ថ្ងៃ យកថ្នាំសម្លាប់ផ្សិតដូចជា Zineb Mancozeb. Captan ទំងន់ ២០ ក្រាម លាយទឹក១៥លីត្រ បាញ់ឱ្យជោគ ទៅលើកូនឪឡឹកខ្ចីៗ ត្រូវប្តូរដីក្នុងការដាំដុះ និងជ្រើសរើសរដូវកាលឱ្យបានសមស្របពេលលេចចេញនូវសញ្ញា ត្រូវបន្ថយការស្រោចទឹក និងបំប៉នដីដែលមានសារធាតុអាសូតច្រើន

**៣. ក្រុមជំងឺបង្កឡើងដោយបាក់តេរី :** បាក់តេរីជាជំងឺមួយដែលឆ្លង និង រីករាលដាលយ៉ាងខ្លាំងព្រមទាំងធ្វើអោយដំណាំខូចខាតជាទំងន់ ។ លើដំណាំឪឡឹកគេសង្កេតឃើញមានបាក់តេរី ២ប្រភេទដូចតទៅ:

- បាក់តេរីធ្វើអោយស្រពោន : មានឈ្មោះហៅថា Bacterial wilt ដែលបង្កឡើងដោយមេរោគឈ្មោះ Erwina tracheipila មេរោគនេះភាគច្រើនរស់នៅក្នុងដី និង







ទឹក វាជ្រៀតចូលទៅដើមដំណាំជាបណ្តើរៗ ចាប់តាំង ពី ដំណាំដុះលូតលាស់ដំបូង ប៉ុន្តែអាចធ្វើអោយឪឡឹកស្រពោន ហើយក្រៀមស្វិតមិនអាចលូតលាស់បន្តទៀតបាន នៅ ក្នុងវគ្គពង្រីកផ្លែ ជាពិសេសនៅតំបន់ខ្ពង់រាប និងភ្នំ ។

- បាក់តេរីបង្កអោយខ្លោចស្លឹក :

ឈ្មោះ Bactrial spot ដែលបង្កឡើងដោយមេរោគឈ្មោះ Pseudontonas syringae pv. Lachrymans ជំងឺនេះតែងតែកើតទៅលើស្លឹក ដើម បង្កើតបានជាចំនុចខ្លោចៗ តូចៗ ដូចប្រជ្រុយ ហើយស្ងួត ធ្វើអោយស្លឹកជ្រុះ ឪឡឹកមិនអាចលូតលាស់បានជាពិសេសនៅដើមរដូវវស្សា អាកាស ធាតុក្តៅសើម ។ ដើម្បីទប់ទល់នឹងជំងឺទាំងនេះ គេត្រូវបាញ់ថ្នាំសំលាប់សត្វល្អិតស្លាបរឹង ដែលស៊ីពីដើម១ទៅដើម Cucumberbeetles ប្រើប្រាស់ពូជធន់ ផ្លាស់ប្តូរដីព្រមទាំងគ្រាប់ពូជដែលគ្មានជាប់មកជាមួយនូវមេរោគ ។ ចំពោះ ជំងឺ Bacterial Spot គេប្រើថ្នាំសម្លាប់ផ្សិតដែលផ្សំឡើងដោយទង់ដែងអុកស៊ីត Copper ពេលលេចចេញសញ្ញាដំបូង ។

កាត់បំផ្លាញដើមដំណាំខ្ចីៗនៅពេលយប់ ។

- ដង្កូវហ្វូងស៊ីស្លឹកនិងផ្លែ វាស៊ីបំផ្លាញស្លឹក ផ្កា ផ្លែខ្ចី ហើយមានលក្ខណៈជាហ្វូងៗ ។

- ដង្កូវមូរស្លឹក ដង្កូវប្រភេទនេះចូលចិត្តជ្រក និង ស៊ីត្រួយខ្ចី ៗគ្រប់ដំណាក់កាលលូតលាស់ ប៉ុន្តែវាអាចស៊ីផ្កា ធ្វើឱ្យរំខានដល់ការបន្តពូជផងដែរ ។

**២.វិធានការការពារ និងកំចាត់ :**

ដើម្បីទប់ទល់ទៅនឹងកត្តាចង្រៃនេះគេត្រូវអនុវត្តវិធានការយ៉ាងច្រើនដូចជា : ជ្រើសរើសរដូវ ផ្លាស់ ប្តូរមុខដំណាំ ជ្រើសរើសពូជធន់ទ្រាំរៀបចំដីអោយបានត្រឹមត្រូវ សំអាតស្មៅក្នុងចំការ ជាពិសេសក្នុងការគ្រប់គ្រងវត្តមានសត្វល្អិតជាប្រចាំមុនពេលវាពេញវ័យ ហើយអាចអនុវត្តវិធានការគីមី ដោយប្រើប្រាស់ថ្នាំពុលកសិកម្មអោយបានសមស្រប ។





## IV. អំពីសត្វល្អិតចង្រៃ និងការការពារ

មានសត្វល្អិតចង្រៃជាច្រើនប្រភេទដែលបំផ្លាញដំណាំក្នុងនោះមានសត្វល្អិតជាភ្នាក់ងារបង្ករោគ និង សត្វ ល្អិតបំផ្លាញផ្ទាល់ ។

**១. សត្វល្អិតជាភ្នាក់ងារបង្ករោគ មានសត្វល្អិតជាច្រើនប្រភេទដែលបំផ្លាញដំណាំហើយបណ្តាលឱ្យកើតជំងឺជាពិសេសជំងឺវីរុសដូចជា :**

- ចៃបៃតង
- ចៃខ្មៅ
- មមាចជញ្ជក់ស្លឹក
- រុយស

ការបំផ្លាញរបស់សត្វល្អិតទាំងនេះភាគច្រើនកកេរ និងកាត់បំផ្លាញទាំង ស្លឹក ផ្កា ផ្លែ ដើម ក្នុងនោះមាន:

- អណ្តើកមាសពណ៌លឿង វាស៊ីស្លឹកកូទីឡេដុង ត្រួយខ្ចីៗ ផ្កានិងក្តិបខ្ចីៗ បន្ថយការលូតលាស់ព្រមទាំងរំខានដល់ការបន្តពូជ ។

- ដង្កូវកាត់ដើម : ដង្កូវប្រភេទនេះច្រើនជ្រកលាក់ខ្លួននៅក្នុងដីពេលថ្ងៃហើយ



## V. ការប្រមូលផល

ដោយយោលទៅលើឪឡឹកជាប្រភេទដំណាំប្រមូលយកផ្លែទុំពេញលក្ខណៈ នៅនឹងដើម ដូចនេះគេត្រូវសំគាល់ទៅលើដៃទាំងពីរអមទងផ្លែ កាលណាវាស្ងួត៧០%ពីខាងចុងទៅគល់ ហើយសំបកនៃផ្លែមានក្រាមម្សៅក្រាស់ នោះជាអាយុកាលដែលអាចប្រមូលបាន ដោយប្រើកាំបិតរឺកន្ត្រៃកាត់ ផ្ដាច់ទង ហើយជញ្ជូនយកទៅរក្សាទុកកន្លែង







ត្រជាក់មិនត្រូវដាក់ឱ្យត្រូវកំដៅថ្ងៃឡើយ ធ្វើអោយបាត់បង់សោភ័ណភាព និងគុណភាព ។ ប្រភេទពូជ ស្រាល មានអាយុពី ៥៥-៦០ ថ្ងៃ ពូជកណ្ដាល ៦៥ ទៅ ៧៥ថ្ងៃ និងពូជធ្ងន់ពី ៨០ ទៅ៩០ថ្ងៃ ក្រោយដាំហើយទិន្នផល ជាមធ្យមពី ១៥ ទៅ ១៧ តោន ១ហត ។



